សូមស្វាគមន៍ពីសង្គមជំនួយផ្នែកច្បាប់នៃមជ្ឈិមភាគញ៉ូយក (Legal Aid Society of Mid-New York, Inc.)។ យើងផ្ដល់ព័ត៌មាន, ដំបូន្មាន, និងធ្វើជាតំណាងទាក់ទងផ្នែកច្បាប់ឲ្យដោយឥតគិតថ្លៃដល់ពលរដ្ឋដែលមិនមានលទ្ធភាពរកមេធាវីដោយខ្លួនឯងបាន។

យើងផ្ដល់ការជួយផ្នែកច្បាប់នៅក្នុងខោនធីទាំងនេះ នៅក្នុងរដ្ឋញ៉ូយកៈ

Broome, Cayuga, Chenango, Cortland, Delaware, Herkimer, Jefferson, Lewis, Madison, Oneida, Onondaga, Oswego, Otsego។

## សូមទស្សនាវិធីអ្វីពីជំនួយផ្នែកច្បាប់

នេះជាឧទាហរណ៍ខ្លះ។ នៃបញ្ហាច្បាប់ដែលយើងអាចជួយបានៈ

- បញ្ហាទាក់ទងនឹងអ្នកប្រើប្រាស់ ដូចជាបញ្ហាទាក់ទងនឹងបំណុល
- បញ្ហាផ្នែកការងារ ដូចជាការប្រកាន់រើសអើងនៅកន្លែងធ្វើការ ឬប្រាក់ឈ្នួលមិនសមរម្យ
- បញ្ហានៅសាលា ដូចជារកគេឲ្យជួយក្នុងសាលាសំរាប់កូនដែលមានភាពពិការ
- បញ្ហាក្នុងគ្រួសារ ដូចជាការលែងលះគ្នា, អាណាព្យាបាលកូន, ប្រាក់ឧបត្ថម្ភកូន, ការឧបត្ថម្ភដល់ប្ដី ឬប្រពន្ធ និងអំពើហិង្សាក្នុងគ្រួសារ
- បញ្ហាក្នុងការស្វែងរកការធានាផ្នែកសុខភាព ឬសេវាកម្មផ្នែកសុខភាព
- បញ្ហាផ្នែកផ្ទះសម្បែង ដូចជាត្រូវម្ចាស់ឲ្យចុះចេញ, ផ្ទះត្រូវគេរឹបអូសយកវិញ និងទាមទារឲ្យម្ចាស់ផ្ទះធ្វើការជួសជុល
- ប្រយោជន៍សាធារណៈ ដូចជាការទទួលជំនួយពីរដ្ឋ, ហ្វូតស្តែម, ប្រាក់សូស្យាល់, SSI, ប្រាក់ជំនួយពេលអត់កិច្ចការធ្វើ និងជំនួយដទៃទៀត
- បញ្ហាផ្នែកឥន្ទោប្រវេសន៍ ដូចជាការចូលសញ្ជាតិអាមេរិកាំង
- បញ្ហាផ្នែកឯកសារច្បាប់ ដូចជាសំបុត្រចែកកេរ្តិ៍មរតក និងសិទ្ធិតំណាងជាផ្លូវច្បាប់

យើងមិនអាចជួយការពារលោក-អ្នកក្នុងករណីបទឧក្រិដ្ឋ ឬក៏ជួយលោក-អ្នកទាក់ទងនឹងសំបុត្រចរាចរណ៍បានឡើយ។ បើសិនជាលោក-អ្នកត្រូវគេចោទពីបទឧក្រិដ្ឋណាមួយ ចូរទាក់ទងការិយាល័យមេធាវីសាធារណៈនៅក្នុងតំបន់ដែលលោក-អ្នករស់នៅ។

ក្នុងករណីភាគច្រើន យើងគ្រាន់តែអាចជួយអ្នកដែលមានប្រាក់ចំណូលទាបតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើសិនជាលោក-អ្នកមានអាយុលើសពី ៦០ឆ្នាំ ឬក៏ជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ លោក-អ្នកប្រហែលជាអាចត្រូវគេជួយបាន បើទោះណាជាលោក-អ្នកមិនមែនជាអ្នកដែលមានប្រាក់ចំណូលទាបក៏ដោយ។

ដើម្បីឲ្យបានទទួលការជួយពីកម្មវិធីរបស់យើង លោក-អ្នកអាចដៀងចូលការិយាល័យរបស់យើងមួយណាក៏បាន។ យើងនឹងមានអ្នកបកប្រែដឹចំណាននៅនឹងកន្លែង ឬតាមទូរស័ព្ទដើម្បីជួយលោក-អ្នកដោយឥតគិតថ្លៃនៅពេលលោក-អ្នកដៀងចូល។

លោក-អ្នកក៏អាចទូរស័ព្ទមកយើងដោយមិនបាច់បង់ប្រាក់តាមលេខ 1-877-777-6152។ សូមប្រាប់បុគ្គលិកយកព័ត៌មានរបស់យើងឲ្យដឹងពីភាសារបស់លោក-អ្នក។ លោក-អ្នកប្រហែលជាត្រូវរង់ចាំតាមទូរស័ព្ទពីរ-បីនាទី ខណៈដែលយើងកំពុងតភ្ជាប់ជាមួយអ្នកបកប្រែ។

ទូទាំងសហរដ្ឋអាមេរិក ថវិកាសំរាប់ការជួយផ្នែកផ្លូវច្បាប់ត្រូវគេកាត់បន្ថយ។ យើងមានមេធាវីជាបុគ្គលិកចំនួនតិច។ ដោយសារហេតុនេះហើយ យើងមិនអាចបំរើដល់បុគ្គលទាំងអស់ដែលសុំឲ្យយើងជួយបានទេ។ *យើងប្រហែលជាមិនអាចទទួលសំណុំរឿងរបស់លោក-អ្នកបានឡើយ។*

យើងជួយអ្នកដែលមានភាពអាសន្នជាមុន។ ឧទាហរណ៍នៃសំណុំរឿងដែលមានភាពអាសន្ននោះគឺ អំពើហិង្សាក្នុងគ្រួសារ, ការដែលត្រូវគេឲ្យចុះចេញពីផ្ទះ និងការបាត់បង់ប្រាក់ជំនួយ។ លើសពីនោះទៀត យើងអាចមានបញ្ជីរង់ចាំសំរាប់សំណុំរឿងដទៃទៀតផងដែរ។

បើសិនជាយើងមិនអាចទទួលសំណុំរឿងរបស់លោក-អ្នកទេ យើងនឹងផ្តល់ព័ត៌មានពីអង្គការដទៃទៀតដែលអាចជួយលោក-អ្នកបាន។

សូមមើលបញ្ជីអាស័យដ្ឋាននៃការិយាល័យរបស់យើង